ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាជំនុំ ព្រហ្មទណ្ឌ

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ៥៥

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៩

សាលដីកា

លេខ: ០៨

ចុះថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ឃឹម ប៉ុណ្ណ ចៅក្រម

៣- លោក សោម សិរីវុឌ្ឍ ចៅក្រម

៤- លោក ប្រាក់ ម៉ឹងសាន ចៅក្រមរបាយការណ៍

៥- លោក យាវ ស្មូរ៉ែន ចៅក្រម

ក្រឡាបញ្ជី លោក ទឹម សុផារិទ្ធិ

តំណាងមហាអយ្យការ លោក ជួន ស៊ុំឡេង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ២២១ ចុះថ្ងៃ ១១ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់ តុលាការកំពូល ។

ពីបទ : បុកប៉ះទង្គិចនាំឲ្យស្លាប់ ដោយអចេតនា ប្រព្រឹត្តកាលពីថ្ងៃទី២៣ ខែ [illegible] ឆ្នាំ១៩៩៩ នៅក្រុងភ្នំពេញ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ជនជាប់ចោទឈ្មោះ ចាង ស៊ែ "ជាចុងចម្លើយបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២១ ឆ្នាំ ជាតិ ខ្មែរ មុខ របរធ្វើបេអឹម ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៣១ ផ្លូវលេខ ៣២០ សង្កាត់អូរឡាពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ មួយ ភៀក "រ" ម្តាយឈ្មោះ ស៊ូ ខេង "រ" នៅរស់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

- មេធាវីគ្មាន ។

- ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ ប្អូត ប៊ួរ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៥ ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ០៦ ក្រុងភ្នំពេញ របរកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ ១៣៤អ៊ី០ ផ្លូវលេខ២៨៦ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ជូ ប្អូត "រ" ម្តាយឈ្មោះ ទៀវ តាន់ "រ" ប្រពន្ធឈ្មោះ លឹម ដួ មានកូន០២នាក់។ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

មេធាវី លោក សុក ទី៣ ការពារក្តីអោយជនរងគ្រោះឈ្មោះ ហួត ហួរ ។

-តាមបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក ហួត ហួរ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ដើមបណ្តឹងរដ្ឋប្បវេណីលោក ហួត ហួរ បានបញ្ជាក់ថា ខ្លួនសុំប្តឹងពីឈ្មោះ ហាំង ស៊ែ, ឈ្មោះ ឡាង និងឈ្មោះ ហាង ងួន ដែលបានប៉ុនប៉ងធ្វើឃាតខ្លួន ដោយហេតុថា កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ វេលាម៉ោង ៣ ០០នាទី ឈ្មោះ ហាំង ស៊ែ បានដើរមកកន្លែងតូបលក់ដូររបស់ខ្លួន រួចនិយាយទៅកាន់ប្រពន្ធរបស់ខ្លួនថា ចែងឯងលួចប្រដាំកូនចែងឯងផង ខ្លួនឮដូច្នេះក៏ដើរចេញសួរឈ្មោះ ហាំង ស៊ែថាមានរឿងអ្វី ស្រាប់តែឈ្មោះហាំង ស៊ែ ស្រែកថា ក្មេងគិតអញ្ចឹងដែរ ក្មេងកុំខ្លាចបាញ់ក្មេងអោយងាប់ ចោលកូនទាំងពីរតែម្តង ទន្ទឹមនឹងនោះដែរឈ្មោះ ឡាង ត្រូវជាក្តាមចឹងរបស់ឈ្មោះ ហាំង ស៊ែ ស្រែកថា ក្មេងបាញ់វាអោយងាប់ទៅនិយាយផុតឈ្មោះហាំង ស៊ែ ក៏ដកកាំភ្លើងខ្លី "មិនស្គាល់ម៉ាក" បាញ់សំដៅខ្លួនតែពុំចំព្រោះខ្លួនគេចផុត រួចឈ្មោះ ឡាង ស្រែកថាបាញ់វាអោយងាប់ទៅយ៉ាងច្រើនអស់ប៉ុន្មាន ៥០០០ដុល្លា ។ ពេលវាបាញ់រួចវាក៏រត់ចេញខ្លួនបាត់តែម្តង ។ លុះក្រោយមកម៉ោងប្រហែល ៩ ០០នាទីយប់ថ្ងៃនោះដែល ឈ្មោះ ហាង ងួន បានទូរស័ព្ទ គំរាមចង់សំលាប់ខ្លួន និងជេរថាអាចុយម្រាយ ក្មេងចង់ងាប់ក្មេង ..អញ្ចាំងសំលាប់ក្មេងចោលកូនទាំងពីរ ។

-បានឃើញ ដីកាតម្កល់រឿងទុកមិនចាត់ការ លេខ ៦០៤ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៨ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ដែលសំរេចតម្កល់រឿងព្រហ្មទណ្ឌលេខ ៨៥ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ទុកមិនចាត់ការ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៨ របស់លោក ហួត ហួរ ដែលប្តឹងតវ៉ាពីដីកាតម្កល់រឿងទុកមិនចាត់ការលេខ ៦០៤ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៨ របស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ដែលសំរេចតម្កល់រឿងព្រហ្មទណ្ឌលេខ ៨៥ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ទុកមិនចាត់ការ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា: រឿងដែលមានផ្ទុះគ្រាប់កាំភ្លើង ១គ្រាប់នេះ គឺផ្ទុះគ្រាប់ចុះទៅដី និងគ្មានទិសដៅ ដូចឈ្មោះ ហាង-ស៊ែ និងសាក្សី បានឆ្លើយថាបណ្តាលមកពីចលនាឃាត់ ដើម្បីប៉ះទៅលើដៃកកាំភ្លើង ។ ដូច្នេះអាចសួរថា តើមានចេតនាដែរឬទេ ? រឿងមានលក្ខណៈជារឿងក៏ពិតងគំរាម ប៉ុន្តែគ្មានបទល្មើស ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១២ - ៩ - ១៩៩៨ របស់ឈ្មោះ ហួត ហួន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់ដីកាសំរេចតម្កល់រឿងទុកឥតចាត់ការ លេខ ៦០៤ ចុះថ្ងៃទី ០៥ - ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ព្រះរាជអាជ្ញាអម តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខ លេខ ៣៩ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់ លោក ហួត ហួន ដែលប្តឹងតវ៉ានឹង សាលដីកាព្រហ្មទណ្ឌលេខ២០១ ចុះថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់ សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សារណាចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់លោក ហួត ហួន ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញ សារណាឆ្លើយតប ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៩ របស់លោក ហាង សែ ជាចុងបណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា : ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងមូលមក មហាអយ្យការយល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈ ត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

- បានស្តាប់អំណានសារណា របស់លោក ហាង សែ ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ។

- បានស្តាប់ចម្លើយអះអាង របស់ លោក ហួត ហួន ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ថា : កាលដែលខ្ញុំបាទប្តឹងសាទុក្ខមកតុលាការកំពូល ព្រោះការសំរេចសេចក្តីកន្លងមកនេះមានភាពអយុត្តិធម៌ណាស់ ហាង សែមានបំណងបាញ់សំលាប់ខ្ញុំបាទយ៉ាងពិតប្រាកដ តែដោយសារតែម្តាយមីងហាង សែ ទះដៃចេញ ម្លេះពេលនោះ ខ្ញុំបាទ បានស្លាប់បាត់ទៅហើយពុំ កាលដែលខ្ញុំបាទរួចខ្លួនមកដល់ពេលនេះ ដោយសារ ថាពេលផ្ទុះអាវុធ អាជីវករ និងអ្នកទិញទំនិញប្រសេចប្រសាច ជាហេតុធ្វើអោយ ហាង សែ ពុំមានលទ្ធភាព បាញ់ខ្ញុំបន្តទៀត ។ ក្រោយពេលផ្ទុះអាវុធ ឈ្មោះ ហាង សែ បានគេចខ្លួនរហូត ខ្ញុំបាទបានប្តឹងទៅទីស្នាក់ការផ្សារអូរឡាំពិក តែឈ្មោះនេះគេចខ្លួន ខ្ញុំបាទក៏ប្តឹងទៅព្រះរាជអាជ្ញា តែព្រះរាជអាជ្ញាពុំព្រម ធ្វើការកោះហៅសាក្សី ដែលនៅជិតនោះមកធ្វើការបញ្ជាក់ គឺហៅតែក្រុមគ្រួសារជនល្មើស មកសួរនាំ តែប៉ុណ្ណោះ ។ ហើយសូម្បីតែហៅខ្ញុំបាទទៅសួរចំលើយ ក៏មានការគំរាមកំហែងដែរ នេះដោយសារតែតុលាការកាន់ជើងជនល្មើស ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពារ របស់លោក សុក ទិត ជាមេធាវីអោយលោក ហួត ហួរ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា: ព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញ មិនបានអង្កេតរកបទល្មើស តាមព្រឹត្តហេតុដែល កើតឡើងនោះឡើយ ហើយថែមទាំងមិនបាន ធ្វើសេចក្តីសន្និដ្ឋាន បញ្ជូនរឿងអោយស៊ើបសួរទៅចៅក្រមតាមមាត្រា៦០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឡើយ ។

អំពើដែលឈ្មោះ ហាង ស៊ែល ប្រព្រឹត្តគឺជាអំពើប៉ុនប៉ងធ្វើមនុស្សឃាត ដែលមានលក្ខណៈពេញលេញ កំណត់ដោយធាតុផ្សំបទល្មើស ដំណាក់កាលនៃការប្រព្រឹត្ត បានឆ្លងបញ្ចប់ពីស្ថានភាពប្រព្រឹត្ត ស្ថានជំរុញអោយប្រព្រឹត្ត អំពើ សកម្មភាពប្រព្រឹត្ត និងមានភស្តុតាងគ្រប់គ្រាន់ សំរាប់ជាមូលដ្ឋានបញ្ជាក់ថាអំពើនេះពិតជាអំពើព្រហ្មទណ្ឌ បទឧក្រិដ្ឋដែលត្រូវបានច្បាប់ចែង និងការពារតាមមាត្រា៣៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ករណីនេះ យោងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ០៧-៨-៩៨ ។

ខ្ញុំសូមអោយលោក មហាអយ្យការ តុលាការកំពូល មេត្តាឯកភាពតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។ សូមអោយតុលាការកំពូល ធ្វើការចោទប្រកាន់ជនល្មើសតាមច្បាប់អោយសមនឹងអំពើប្រព្រឹត្ត កាលពីថ្ងៃទី ២៦-០១-១៩៩៨ ។ សូមអោយឃុំខ្លួនជនល្មើស ដកហូតឧបករណ៍ប្រព្រឹត្តល្មើស និងផ្តន្ទាទោសជនល្មើស ពីបទអាជ្ញាតតិតាមបញ្ញត្តិច្បាប់ខាងលើ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: តំណាងមហាអយ្យការ ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ ចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សារណាតបរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា: បណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក ហួត ហួរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្តី ។

- យល់ឃើញថា: លទ្ធផលនៃការស៊ើបអង្កេត របស់អយ្យការ អម តុលាការក្រុងភ្នំពេញ ពុំបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ដូចការចោទប្រកាន់ របស់ លោក ហួត ហួរ ក្នុងសារណាចុះថ្ងៃទី ២៤-១២-៩៨ ដែលថា ឈ្មោះ ហាង ស៊ែល បានបាញ់មកលើលោកចំនួន០១ គ្រាប់ ហើយក្រោយពេលបាញ់ រកឱកាសបាញ់សំដៅសម្លាប់លោក ០១គ្រាប់ទៀតនោះឡើយ ។

- យល់ឃើញថា: ជនជាប់ចោទបាន ធ្វើសារណាតបជូនមកតុលាការកំពូល និងបានទទួលដីកា

កោះរួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១-៩-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងអង្គច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខៈ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក បួត-បួរ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងអង្គច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១-៩-៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះប្រកាស នាសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ - ខែ មិនា ឆ្នាំ ១៩៩៩ ។